SAFE ROUTES to School
TACOMA, WA

ដើរនិងជិះ ទៅ សាលារៀនពេលថ្ងៃ

ចូលរួមពិធីបុណ្យ។ ដើរឬជិះទៅសាលារៀន នៅ៖

នៅពេលដែលអ្នកដើរឬជិះទៅសាលារៀន៖

- ខួរក្បាលរបស់អ្នកទទួលបានការបង្កើនថាមពល។
- អ្នកមានពេលជជែកជាមួយមិត្តភក្តិឬក្រុមគ្រួសារ។
- អ្នកជួយថែរក្សាផែនដី។

TACOMA PUBLIC SCHOOLS EVERY STUDENT. EVERY DAY.

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីផ្លូវសុវត្ថិភាពទៅសាលារៀនក្នុងទីក្រុងតាកូម៉ា
សូមចូលទៅកាន់ cityoftacoma.org/SRTS

CITY OF Tacoma

គោះទៅសាលា ដោយសុវត្ថិភាព

SAFE ROUTES to School
TACOMA, WA

ក្រុង Tacoma អបអរសាទរចំពោះអ្នកដំណើរថ្មើរជើង និងអ្នកជិះកង់ តាមរបៀបធម្មតា និងដោយរីករាយ ពេលទៅសាលារៀន។

ដើរដោយសុវត្ថិភាព

STOP

ឈប់តាមផ្លាកសញ្ញានៅគែមផ្លូវ ឬចិ ញ្ចើ មផ្លូវ

មើលឆ្វេង ស្តាំ ឆ្វេង និងខាងក្រោយអ្នក

មើលអ្នកបើកឡានដែ លនៅកៀកជិ តអ្នក

ឆ្លងផ្លូវនៅកាច់ជ្រុង ឬនៅ ចិញ្ចើមផ្លូវណាដែលមាន គំនូសឆ្លង

ជិះដោយសុវត្ថិភាព

អាចគណនា ១ជាមុន

អនុវត្តតាមច្បាប់ចរាចរណ៍ ហើយឈប់នៅមុខផ្លាកសញ្ញា stop ទាំងអស់។ នៅក្នុងក្រុង Tacoma អ្នកជិះកង់ត្រូវបានគេអនុញ្ញាតឱ្យជិះ នៅលើចិញ្ចើ មផ្លូវដើរថ្មើជើងបាន។ ចូរពិភាក្សាជាមួយមនុស្ស ពេញវ័យដែលគួរឱ្យទុកចិត្ត ថាតើត្រូវជិះលើផ្លូវ ឬជិះលើចិញ្ចើមផ្លូវ តាមបណ្តាយផ្លូវទៅសាលារៀនរបស់អ្នក។

ចូរប្រុងប្រយ័ត្នជាមួយចរាចរណ៍តាមផ្លូវ។ ជិះបណ្តោយក្នុងទិសដៅ តែមួយជាមួយឡាន។

ជិះនៅខាងស្តាំក្នុងផ្លូវបន្ទាត់ត្រង់សំរាប់អ្នកជិះកង់។ ជៀសវាងកុំឲ្យទៅបុក ទ្វារឡានៅពេលដែលអ្នកចតរថយន្តបើ កទ្វារចេញក្រៅ។

បើជិះពេលយប់ **សូមបើកភ្លើងកង់**។

សូមពាក់មួកសុវត្ថិភាពរបស់អ្នក

មួកសុវត្ថិភាពរបស់អ្នកត្រូវតែគ្របលើ ថ្ងាស និងគ្របនៅត្រឹមខាងលើចិញ្ចើម របស់អ្នក។

ទាញខ្សែមួកសុវត្ថិភាពជាអក្សរ V ដាក់ នៅត្រចៀករបស់អ្នក រួចដាក់គន្លឹះ។

រឹតបន្តឹងខ្សែរដើម្បី ឲ្យវាកិប ជាប់ក្រោមចង្ការបស់អ្នក។

ប្រើដៃជាសញ្ញា

បត់ស្តាំ	បន្ថយល្បឿន ឬឈប់	បត់ឆ្វេង

បើកដោយសុវត្ថិភាព

SPEED LIMIT 20

បន្ថយល្បឿន

សូមប្រយ័ត្ននិងឈប់ពេល សិស្សនិងក្រុមគ្រួសារ ឆ្លងកាត់ផ្លូវ។

ចតដោយសុវត្ថិភាព

ចត ឈប់ និងទទួលកូនសិស្ស នៅកន្លែងដែលគេបានអនុញ្ញាត ឱ្យប៉ុណ្ណោះ។

អនុវត្តតាមច្បាប់ចរាចរណ៍

ជៀសវាងការបត់ត្រឡប់ក្រោយ និងហាមឈប់នៅលើ ផ្លូវដែលមានគំនូសឆ្លងកាត់ កន្លែងចេញចូលចតរថយន្ត បំពង់ពន្លត់អគ្គីភ័យតាមផ្លូវ ចំណតឡានក្រុង និងផ្លូវ ចេញចូលមុខផ្ទះ។

TACOMA PUBLIC SCHOOLS EVERY STUDENT. EVERY DAY.

ចូរស្វែងយល់បន្ថែមអំពីផ្លូវទៅសាលារៀនដែលមានសុវត្ថិភាពក្នុងក្រុង Tacoma នៅ៖
cityoftacoma.org/SRTS

CITY OF Tacoma